ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៤៧ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣នេះ បានដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ រហូតដល់ថ្ងៃទី១៥ ខែកក្កដា និងបន្តពន្យារពេលបង់ពន្ធរហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣នេះ ។ ក្នុងអំឡុងពេលប្រកាសបង់ពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា មានម្ចាស់យានយន្ត ភាគច្រើនបានមកបំពេញកាតព្វកិច្ចនេះ ។

ដើម្បីឱ្យការប្រមូលពន្ធសម្រាប់ឆ្នាំ២០១៣នេះ ប្រព្រឹត្តទៅបានល្អប្រសើរនាពេលជិតផុតកំណត់នៃកាលបរិច្ឆេទត្រូវបង់ពន្ធនោះ អគ្គនាយកដ្ឋានពន្ធដារសូមរំលឹកដល់ម្ចាស់យានយន្តគ្រប់ប្រភេទដែលមិនទាន់បានទៅប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ មេត្តារួសរាន់អញ្ជើញទៅបង់ពន្ធនេះ ទៅតាមទីតាំងរបស់រដ្ឋបាលពន្ធដារ ចំពោះរថយន្តគ្រប់ប្រភេទ និងនៅតាមបញ្ជរធនាគារ អេស៊ីលីដា ភីអិលស៊ី ចំពោះត្រីចក្រយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ ឱ្យបានមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ នេះ ។

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ តទៅ អង្គភាពពន្ធដារនឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ ដោយអនុវត្តការផាកពិន័យបន្ថែមលើប្រាក់ពន្ធស្មើនឹង ១០០ ភាគរយ នៃប្រាក់ពន្ធដែលត្រូវបង់ ចំពោះយានយន្តទាំងឡាយណាដែលម្ចាស់មានការយឺតយ៉ាវមិនបានមកប្រកាសបង់ពន្ធនេះ ។

ដូចនេះ សូមអស់លោក-លោកស្រី ជាម្ចាស់យានយន្តទាំងអស់ មេត្តារួសរាន់អញ្ជើញទៅប្រកាសបង់ពន្ធឱ្យបានរួចរាល់ដូចបានជម្រាបជូនខាងលើ ចៀសវាងនូវការប្រជ្រៀតគ្នាបង់ពន្ធនៅពេលចុងកាលបរិច្ឆេទកំណត់ ដែលនាំឱ្យមានការខកខានពុំបានបង់ពន្ធទាន់ពេលវេលា ។

អគ្គនាយកដ្ឋានពន្ធដារមានក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ជាម្ចាស់យានយន្តទាំងអស់មានស្មារតីគោរពច្បាប់ និងអញ្ជើញមកប្រកាសបង់ពន្ធបានតាមកាលកំណត់ខាងលើ ជាពុំខាន ។-

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល